001/18-07-2007-ECCC/TC
E1/22

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 06 / 2009
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. [signature]

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>
# <u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"</u>

<u>សាធារណៈ:</u>

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩-ថ្ងៃទី ១៨

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 18 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. [signature]

រៀបចំដោយ: សែ កុលវុឌ្ឍី និង Natacha-Wexel-Riser

| |
|---|
| <u>កំណត់ហេតុអ្នកចូលរួម</u> |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Matteo CRIPPA, កញ្ញា Natacha-Wexel-Riser លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក តាន់ សេណារ៉ុង, លោក Alexander Bates |

| |
|---|
| លោក ពេជ្រ សម្បត្តិ,លោក ប៉ាក ចន្ទលីណូ,លោក Stuart Ford |
| ជនជាប់ចោទ៖ កាំង ហ្គេកអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ,លោក François Roux, លោកស្រី Heleyn Unac លោក ចាន់ រ៉ាវុធ កញ្ញា Lucile Nattiez |
| មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក គង់ ពិសី, លោក ហុង គីម សួន,យុង ផានិត,កញ្ញា Silke Studzinsky, លោក Alain Werner,កញ្ញា ទី ស្រីនណា, លោកស្រី Elisabeth Rabesandratana,លោក គីម ម៉េងឃី |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក ខូវ កែវរតនៈ |
| ផ្នែកផ្សេងៗ៖ លោកស្រី Julie Massé, លោកស្រី Maryvonne Maniacky, លោក ខែម លីនដារីតា |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩ | ចាប់ផ្ដើមម៉ោង៖ ១០.៥៥ | បញ្ចប់ម៉ោង៖ ១៦.៤៥ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.០០ | បញ្ចប់ម៉ោង៖ ១៣.៥០ |
| សម្រាកល្ងាច | ចាប់ផ្ដើមម៉ោង៖ ១៥.០៥ | បញ្ចប់ម៉ោង៖ ១៥.២០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០២ ម៉ោង ៤៥ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| សេចក្ដីសម្រេចលើបញ្ហាផ្សេងៗដែលពន្យារការសម្រេច | អង្គជំនុំជម្រះ | ១៣.៥០ | ១៤.០៥ |
| ការបន្តតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុនៃការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ | អង្គជំនុំជម្រះ | ១៤.០៥ | ១៤.៥៣ |
| ការតាំងសំណួរទៅអ្នកជំនាញ | សហព្រះរាជអាជ្ញា | ១៥.២៥ | |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

| | | | |
|---|---|---|---|
| Craig Etcheson ទាក់ទងនឹងអង្គហេតុនៃការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ | | | |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សេចក្ដីសម្រេចដោយផ្ទាល់មាត់ស្ដីពីភាពអាចទទួលយកបាននៃឯកសារក្នុងសំណុំរឿងធ្វើជាភស្តុតាង</u>**

- អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចដោយផ្ទាល់មាត់ស្ដីពីភាពអាចទទួលយកបាននៃឯកសារក្នុងសំណុំរឿងធ្វើជាភស្តុតាង(សូមមើលខាងក្រោម)។

**<u>សេចក្ដីសម្រេចលើសំណើសុំការណែនាំពីអង្គជំនុំជម្រះដោយសហព្រះរាជអាជ្ញា</u>**

- អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាស្ដីពីការណែនាំពីអង្គជំនុំជម្រះ(សូមមើលខាងក្រោម)។

**<u>ការតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ ដោយអង្គជំនុំជម្រះ</u>**

- អ្នកជំនាញ Craig Etcheson បានធ្វើសេចក្ដីសង្ខេបទៅនឹងផ្នែកទាំងឡាយនៃរបាយការណ៍ D2.15/66 ដែលមិនទាន់បានពិភាក្សាពេញលេញនៅពេលសវនាការនៅឡើយ។

**<u>បញ្ហាផ្សេងៗ</u>**

- អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីថា អ្នកជំនាញ Nayan Chanda នឹងផ្ដល់សក្ខីកម្មនៅថ្ងៃទី ២៥ និង ២៦ ខែឧសភា ទៅលើអង្គហេតុនៃជម្លោះប្រដាប់អាវុធ។

**<u>ការតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ ដោយសហព្រះរាជអាជ្ញា</u>**

- សហព្រះរាជអាជ្ញាបានតាំងសំណួរទៅអ្នកជំនាញ Craig Etcheson ទាក់ទងនឹងអង្គហេតុនៃការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១។

| កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីនៃវិធាន ៨៧.២ | | | | |
|---|---|---|---|---|
| លេខយោងអង្គជំនុំជម្រះ | លេខយោងសហចៅក្រមស៊ើបអង្កេត | ឈ្មោះ/ពិពណ៌នា | ចំណាត់ថ្នាក់នៃឯកសារ សម្ងាត់ដាច់ខាត,សម្ងាត់ សាធារណៈ: | ផ្សេងៗ |
| E3/45 | IS 2.1 | ការដាក់ឯកសារពីរដ្ឋាភិបាលទៅអង្គការសហប្រជាជាតិអាមេរិក | សាធារណៈ: | 00087610-00087627 |
| E3/46 | IS 2.3 | "ការដាក់ជូនរបស់រដ្ឋាភិបាលន័រវេជូនគណ:កម្មាការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ" | សាធារណៈ: | 00087537-00087571 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

**I-សេចក្តីសម្រេចដោយផ្ទាល់មាត់ស្តីពីភាពអាចទទួលយកបាននៃឯកសារនៅក្នុងសំណុំរឿងជាភស្តុតាង**

អង្គជំនុំជម្រះសាលាដំបូង ថ្មីៗនេះបានទទួលសំណើពីសហព្រះរាជអាជ្ញា សុំប្រើឯកសារចំនួនបីជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ។ សំណើទាំងនោះដែលត្រូវបានជំទាស់ដោយសហមេធាវីការពារក្តី គឺជាសំណើសុំប្រើប្រាស់ឯកសារដូចខាងក្រោមនេះ៖

ក) ចម្លើយរបស់សាក្សីដែលបានស្លាប់ចំនួនពីរនាក់ ដែលបានកត់ត្រាដោយតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាល ដែលចម្លើយនោះត្រូវបានដាក់នៅក្នុងសំណុំរឿងជាឯកសារលេខ D59/4 និង D59/12 ។

ខ) ចម្លើយរបស់ជនជាប់ចោទ ដែលកត់ត្រានៅក្នុងខែឧសភា ឆ្នាំ១៩៩៩ ដោយតំណាងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHCHR) ដែលចម្លើយ

នោះបានត្រូវដាក់ក្នុងសំណុំរឿងជាឯកសារ D9 ។ អង្គជំនុំជម្រះសាលាដំបូង ក៏បានទទួលសំណើបន្ថែមមួយទៀតរបស់សហព្រះរាជអាជ្ញា ដើម្បីសុំការអនុញ្ញាតិប្រើប្រាស់ឯកសារលេខ 19/25 ដែលគេហៅថារបាយការណ៍ ឈឺន សុទ្ធី នៅចំពោះមុខអង្គជំនុំជម្រះ ។ សេចក្តីសម្រេចលម្អិតជាលាយលក្ខណ៍អក្សរដោយមានសំអាងហេតុស្តីពីបញ្ហាទាំងនេះត្រូវបានពិនិត្យរួចរាល់ហើយដោយអង្គជំនុំជម្រះសាលាដំបូង ហើយនិងត្រូវចេញនៅពេលការបកប្រែត្រូវបានបញ្ចប់ភ្លាម ។

ទន្ទឹមនឹងនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ពាក់ព័ន្ធនឹងសំណើទាំងនេះដូចខាងក្រោម៖

1. អង្គជំនុំជម្រះសម្រេចទទួលសំណើរបស់មេធាវីការពារក្តី ទាក់ទងនឹងចម្លើយរបស់សាក្សីដែលបានទទួលមរណភាព គឺអត្ថបទពាក់ព័ន្ធដែលចេញផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam និងបទសម្ភាសន៍ដែលធ្វើដោយឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ UNHCHR ប៉ុន្តែមិនយកឯកសារទាំងនេះមកធ្វើជាភស្តុតាងទេ ផ្អែកតាមវិធាន៨៧.៣ នៃវិធានផ្ទៃក្នុង។
2. ទទួលសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាទាក់ទងនឹងរបាយការណ៍អំពី ឈឺន សុទ្ធី និងអនុញ្ញាតិឱ្យលើកយកឯកសារនេះនៅចំពោះមុខអង្គជំនុំជម្រះដែលជាកម្មវត្ថុនៃការដេញដោលស្របតាម វិធាន៨៧.២ នៃវិធានផ្ទៃក្នុង ។
3. បង្គាប់ឱ្យការិយាល័យសហព្រះរាជអាជ្ញាផ្តល់របាយការណ៍ពី ឈឿន សុទ្ធី បកប្រែដែលជាសំណៅដើមដល់មេធាវីការពារក្តី ។

## II-សេចក្តីសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំការណែនាំពីអង្គជំនុំជម្រះ

ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំការណែនាំពីអង្គជំនុំជម្រះសាលាដំបូងអំពីវិធីសាស្ត្រនៃការដាក់ឯកសារទាក់ទងទៅនឹងការធ្វើសក្ខីកម្មរបស់អ្នកជំនាញបណ្ឌិត Craig Etcheson នៅចំពោះមុខអង្គជំនុំជម្រះ ។ ការិយាល័យសហព្រះរាជអាជ្ញាបានជូនដំណឹងអំពីបញ្ជីឯកសារដែលមានចំនួន

១៤៨ ដែលមានលេខឯកសារ E55.1 ដែលការិយាល័យនេះមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ បញ្ជីឯកសារទាំងនោះ បានបង្ហាញនូវព័ត៌មានពេញលេញចំពោះឯកសារនីមួយៗ ដូចជាស្ថានភាពនៃការបកប្រែភាសាដើម និងសេចក្តីសង្ខេបនៃឯកសារនីមួយៗលើកលែងតែឯកសារលេខ៤ ។

អង្គជំនុំជម្រះសាលាដំបូង សូមថ្លែងអំណរគុណផងដែរ នូវកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញាក្នុងការជួយដល់អង្គជំនុំជម្រះ និងភាគីក្នុងការរៀបចំឯកសារដែលមានចំនួនដ៏ច្រើននៅក្នុងសំណុំរឿង និងសូមជំរុញដល់ការិយាល័យនេះ ឱ្យបន្តនូវកិច្ចការរបស់ខ្លួនក្នុងការច្របាច់បញ្ចូលនូវឯកសារទាំងនេះតទៅទៀត ។

ជាការឆ្លើយតបទៅនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ឥឡូវនេះអង្គជំនុំជម្រះសាលាដំបូងដាក់ចេញនូវការណែនាំរបស់ខ្លួនទាក់ទងនឹងការជូនដំណឹងនេះដូចតទៅ៖

១) វិធាន៨៧.២ និង ៨៧.៣ គឺជាមូលដ្ឋានគ្រឹះក្នុងដំណើរការសវនាការប្រកបដោយភាពយុត្តិធម៌ ។ ឯកសារដែលភាគី ឬអង្គជំនុំជម្រះមានបំណងយកមកប្រើ ដើម្បីគាំទ្រដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវតែយកមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ហើយត្រូវបានអានទាំងមូល ឬត្រូវបានសង្ខេប មានតែឯកសារ ឬផ្នែកនៃឯកសារដែលបានយកមកដេញដោល នៅចំពោះមុខអង្គជំនុំជម្រះតាមវិធីនេះ ហើយដែលឯកសារនោះជាកម្មវត្ថុនៃការពិភាក្សាដេញដោលតែប៉ុណ្ណោះ ទើបត្រូវបានចាត់ទុកថា បានដេញដោលជាផ្លូវការនៅចំពោះមុខអង្គជំនុំជម្រះ ។

លក្ខខណ្ឌនៃវិធាន៨៧.២ ដែលថា ឯកសារណាមួយជាកម្មវត្ថុនៃការពិភាក្សា គឺត្រូវបានបំពេញទាំងស្រុងនៅពេលដែលមិនមានការជំទាស់ ។ មានតែផ្នែកនៃឯកសារដែលបានសង្ខេបនោះប៉ុណ្ណោះដែលត្រូវចាត់ទុកថា បានដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ។ ឧទាហរណ៍ ប្រសិនបើជំពូកណាមួយនៃសៀវភៅត្រូវបានសង្ខេបគឺមានតែផ្នែកនេះទេ ដែលត្រូវបានចាត់ទុកថាបានយកមកដេញដោល ប៉ុន្តែប្រសិនបើការពិភាក្សាលើឯកសារនោះហួសពីវិសាលភាពនៃការសង្ខេបបឋមនោះ អង្គជំនុំជម្រះអាចយកការពិភាក្សាទាំងមូលនោះមកធ្វើជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួនបាន ។ នៅពេលដែល

ឯកសារត្រូវបានយកមកដេញដោល ភាគីដែលបានបង្ហាញឯកសារនោះត្រូវបញ្ជាក់ថា តើខ្លួនសុំឱ្យមានការពិចារណាឯកសារទាំងមូល ឬក៏មិនពិចារណា ? ប្រសិនបើភាគីសុំបង្ហាញតែផ្នែកណាមួយនៃឯកសារ ឯកសារនោះត្រូវចង្អុលបង្ហាញអំពីផ្នែកដែលពាក់ព័ន្ធនោះ ។ នៅពេលដែលឯកសារណាមួយដាក់នៅចំពោះមុខអង្គជំនុំជម្រះ ភាគីមានសិទ្ធិក្នុងជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារនោះដោយបញ្ជាក់នូវមូលហេតុសមស្រប ។ ភាគីក៏មានសិទ្ធិផងដែរនូវការស្នើសុំព័ត៌មានបន្ថែម ឬការបញ្ជាក់ណាមួយទាក់ទងនឹងឯកសារ ដែលភាគីណាមួយមានបំណងដាក់ជូននៅចំពោះមុខតុលាការ ។

ជារួមបញ្ជីឯកសារដែលបានដាក់បញ្ចូលគ្នាក្នុងឯកសារ E55 គឺមិនមានភាពគ្រប់គ្រាន់សម្រាប់គោលបំណងនៃវិធាន៨៧ ក្នុងការចាត់ទុកជាឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ ។ ឯកសារនីមួយៗត្រូវតែបានសង្ខេបដើម្បីឱ្យភាគីនិងអង្គជំនុំជម្រះមានឱកាសវាយតម្លៃលើឯកសារនោះ ។

២) ជាគោលការណ៍ ឯកសារដែលបានសង្ខេបនោះ គួរតែមានជាភាសាខ្មែរ ពីព្រោះភាសាខ្មែរគឺជាភាសាផ្លូវការរបស់តុលាការ និងជនជាប់ចោទ ។

៣) សូមរំឭកដល់ភាគីទាំងអស់ថា មាត្រា១៥ នៃអនុសញ្ញាស្តីពីការហាមឃាត់ការធ្វើទារុណកម្ម បានចែងថា “*ភាគីរដ្ឋត្រូវធានាថា ឯកសាររបាយការណ៍ទាំងឡាយដែលបង្កើតឡើងបានមកពីអំពើទារុណកម្មមិនត្រូវយកមកសំអាង ជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ ដែលបានធ្វើឡើងដោយសារការធ្វើទារុណកម្ម ។ លើកលែងតែឯកសាររាយការណ៍នោះត្រូវបានធ្វើឡើងសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម*” ។

III-ដីកាបង្គាប់ឱ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៩ ។

**ដីកាសម្រាប់ការលើកវារកាលសវនាការ**

ការពន្យារពេលសវនាការ៖ សវនាការនៅពេលព្រឹកត្រូវបានពន្យាររហូតដល់ម៉ោង ១៣.៣០ នាទី

| សវនាការនឹងបន្តទៅថ្ងៃព្រហស្បតិ៍ ទី២១ ខែឧសភា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ព្រឹក ។ |
|---|

ភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ កុសល វឌ្ឍី Natacha-Wexel-Riser